ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: 0001 រ៉ែ.ឧ.ក/ស.ល.ន

# សេចក្តីណែនាំ
# ស្តីពី
# ការដាក់ប្រាក់តម្កល់ធានាកាតព្វកិច្ច
# សម្រាប់អាជ្ញាបណ្ណស្វែងរុករក

អនុលោមតាមអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណស្វែងរុករកនិងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ និងក្នុងគោលបំណងឱ្យការដាក់ប្រាក់តម្កល់ធានាកាតព្វកិច្ចនេះប្រកបដោយសមធម៌និងតម្លាភាពចំពោះគ្រប់សម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកទាំងអស់ ក្រសួងរ៉ែនិងថាមពល សូមកំណត់នូវគោលការណ៍ នីតិវិធី និងលក្ខខណ្ឌ អនុវត្តសម្រាប់ការដាក់ ការរឹបអូស និងការដក ប្រាក់តម្កល់ធានាកាតព្វកិច្ចដូចខាងក្រោម៖

## ក. គោលការណ៍នៃការដាក់ប្រាក់តម្កល់ធានាកាតព្វកិច្ច

ប្រាក់តម្កល់ធានាកាតព្វកិច្ចសម្រាប់អាជ្ញាបណ្ណស្វែងរុករក ធ្វើឡើងក្នុងគោលបំណងឱ្យសម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករក (ហៅកាត់ថាសម្បទានិក) អនុវត្តកាតព្វកិច្ច ដោយអនុលោមតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងលក្ខខណ្ឌអាជ្ញាបណ្ណ ដែលមានជាធរមាន។ ការដាក់ប្រាក់តម្កល់ធានាកាតព្វកិច្ច នឹងជំរុញឱ្យសម្បទានិកលើកកម្ពស់ការទទួលខុសត្រូវ ក្នុងការធ្វើប្រតិបត្តិការស្វែងរុករករ៉ែ ស្របតាមកម្មវិធីការងារ និងផែនការចំណាយថវិកា ដែលទទួលបានការយល់ព្រមពីក្រសួងរ៉ែនិងថាមពល ក្នុងសុពលភាពអាជ្ញាបណ្ណរបស់ខ្លួន ចាប់ពីដំណាក់កាលដំបូង រហូតដល់ដំណាក់កាលបញ្ចប់នៃការស្វែងរុករក។

## ខ. ការកំណត់ទំហំប្រាក់តម្កល់ធានាកាតព្វកិច្ច

សម្បទានិកត្រូវដាក់ប្រាក់តម្កល់ធានាកាតព្វកិច្ច សម្រាប់រយៈពេលសុពលភាពនៃអាជ្ញាបណ្ណស្វែងរុករកនីមួយៗ។ ទំហំប្រាក់តម្កល់ធានាកាតព្វកិច្ច ត្រូវបានកំណត់ដូចខាងក្រោម៖

- ស្មើនឹង១០%(ដប់ភាគរយ) នៃទំហំកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាសម្រាប់អាជ្ញាបណ្ណលើកទី១
- ស្មើនឹង៧%(ប្រាំពីរភាគរយ) នៃទំហំកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាសម្រាប់អាជ្ញាបណ្ណលើកទី២
- ស្មើនឹង៦%(ប្រាំមួយភាគរយ) នៃទំហំកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាសម្រាប់អាជ្ញាបណ្ណលើកទី៣ និង



លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh

- ស្មើនឹង៥%(ប្រាំភាគរយ) នៃទំហំកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាសម្រាប់អាជ្ញាបណ្ណលើកទី៤ឡើងទៅ។

ស្របតាមមាត្រា៣៥ នៃអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ ទំហំកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាក្នុងប្រតិបត្តិការស្វែងរុករករ៉ែ បានកំណត់ដូចខាងក្រោម៖

- ចាប់ពីឆ្នាំទី១ ដល់ឆ្នាំទី៣ យ៉ាងតិច ១ ០០០ ០០០(មួយលាន)រៀល ក្នុងផ្ទៃដីមួយគីឡូម៉ែត្រការ៉េ នៃដែនអាជ្ញាបណ្ណក្នុងមួយឆ្នាំ ហើយក្នុងករណីដែនអាជ្ញាបណ្ណតូចជាង ១០០(មួយរយ) គីឡូម៉ែត្រការ៉េ នោះកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាមិនត្រូវតិចជាង ១០០ ០០០ ០០០ (មួយរយលាន)រៀលក្នុងមួយឆ្នាំសម្រាប់ដែនអាជ្ញាបណ្ណទាំងមូល
- ចាប់ពីឆ្នាំទី៤ ដល់ឆ្នាំទី៥ យ៉ាងតិច ៤ ០០០ ០០០ (បួនលាន)រៀល ក្នុងផ្ទៃដីមួយគីឡូម៉ែត្រការ៉េ នៃដែនអាជ្ញាបណ្ណក្នុងមួយឆ្នាំ ហើយក្នុងករណីដែនអាជ្ញាបណ្ណតូចជាង ១០០(មួយរយ) គីឡូម៉ែត្រការ៉េ នោះកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាមិនត្រូវតិចជាង ៤០០ ០០០ ០០០(បួនរយលាន)រៀលក្នុងមួយឆ្នាំសម្រាប់ដែនអាជ្ញាបណ្ណទាំងមូល
- ចាប់ពីឆ្នាំទី៦ ដល់ឆ្នាំទី៧ យ៉ាងតិច ៦ ០០០ ០០០ (ប្រាំមួយលាន)រៀល ក្នុងផ្ទៃដីមួយគីឡូម៉ែត្រការ៉េ នៃដែនអាជ្ញាបណ្ណក្នុងមួយឆ្នាំ ហើយក្នុងករណីដែនអាជ្ញាបណ្ណតូចជាង ១០០(មួយរយ) គីឡូម៉ែត្រការ៉េ នោះកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាមិនត្រូវតិចជាង ៦០០ ០០០ ០០០(ប្រាំមួយរយលាន)រៀលក្នុងមួយឆ្នាំសម្រាប់ដែនអាជ្ញាបណ្ណទាំងមូល
- ចាប់ពីឆ្នាំទី៨តទៅ យ៉ាងតិច ១០ ០០០ ០០០(ដប់លាន)រៀល ក្នុងផ្ទៃដីមួយគីឡូម៉ែត្រការ៉េ នៃដែនអាជ្ញាបណ្ណក្នុងមួយឆ្នាំ ហើយក្នុងករណីដែនអាជ្ញាបណ្ណតូចជាង ១០០(មួយរយ) គីឡូម៉ែត្រការ៉េ នោះកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាមិនត្រូវតិចជាង ១ ០០០ ០០០ ០០០ (មួយពាន់លាន)រៀលក្នុងមួយឆ្នាំសម្រាប់ដែនអាជ្ញាបណ្ណទាំងមូល។

សម្រាប់សុពលភាពនៃអាជ្ញាបណ្ណដែលបានពន្យារបន្ត សម្បទានិកត្រូវដាក់ប្រាក់តម្កល់ធានាកាតព្វកិច្ចបង្គ្រប់ស្របតាមទំហំប្រាក់តម្កល់ធានាកាតព្វកិច្ចដែលបានកំណត់សម្រាប់សុពលភាពអាជ្ញាបណ្ណបន្ទាប់។ ក្នុងករណីទំហំប្រាក់តម្កល់ធានាកាតព្វកិច្ចសម្រាប់សុពលភាពអាជ្ញាបណ្ណបន្ទាប់ តិចជាងទំហំប្រាក់តម្កល់ធានាកាតព្វកិច្ចដែលមានស្រាប់ ត្រូវកំណត់យកប្រាក់តម្កល់ធានាកាតព្វកិច្ចស្មើនឹងប្រាក់តម្កល់ធានាកាតព្វកិច្ចដែលមានស្រាប់នោះ។

ចំពោះប្រភេទចំណាយប្រតិបត្តិការអប្បបរមាក្នុងប្រតិបត្តិការស្វែងរុករករ៉ែ ដែលអនុញ្ញាតឱ្យយកមកគិតបញ្ចូលក្នុងចំណាយប្រតិបត្តិការអប្បបរមា ត្រូវអនុវត្តតាមមាត្រា៩១ នៃអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦។

**គ. នីតិវិធីដាក់ប្រាក់តម្កល់ធានាកាតព្វកិច្ច**

មុនពេលទទួលបានអាជ្ញាបណ្ណស្វែងរុករកដំបូងឬអាជ្ញាបណ្ណពន្យារបន្ត សម្បទានិកត្រូវដាក់ប្រាក់តម្កល់ធានាកាតព្វកិច្ច ដោយត្រូវបង់ចូលទៅគណនីទោលនៃរតនាគារជាតិលេខ ០០០០០០០១៣៤៥០ របស់អគ្គនាយកដ្ឋានរតនាគារជាតិ នៅធនាគារជាតិនៃកម្ពុជា បន្ទាប់ពីទទួលបានលិខិតជូនដំណឹងរបស់ក្រសួងរ៉ែនិងថាមពល។



លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh

បន្ទាប់ពីបានតម្កល់ប្រាក់ធានាកាតព្វកិច្ចខាងលើនេះរួច សម្បទានិកត្រូវយកច្បាប់ថតចម្លងនៃ «បណ្ណបញ្ជាក់បានតម្កល់ប្រាក់» មកជូនក្រសួងរ៉ែនិងថាមពល ដើម្បីពិនិត្យនិងទុកជាឯកសារ។

**ឃ. នីតិវិធីនៃការរឹបអូសប្រាក់តម្កល់ធានាកាតព្វកិច្ច**

អនុលោមតាមមាត្រា៣២ នៃអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ ប្រាក់តម្កល់ធានាកាតព្វកិច្ច នឹងត្រូវរឹបអូសជាប្រយោជន៍របស់រដ្ឋ ក្នុងករណីដែលអាជ្ញាបណ្ណស្វែងរុករកត្រូវបានដកហូត។ ក្រសួងរ៉ែនិងថាមពល នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការរឹបអូសប្រាក់តម្កល់ធានាកាតព្វកិច្ចជូនដល់សម្បទានិក និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានរតនាគារជាតិ) ដើម្បីអនុវត្តនីតិវិធីរឹបអូសទុកជាប្រយោជន៍របស់រដ្ឋ។

**ង. នីតិវិធីនៃការដកប្រាក់តម្កល់ធានាកាតព្វកិច្ច**

សម្បទានិក អាចត្រូវបានអនុញ្ញាតឱ្យដកប្រាក់តម្កល់ធានាកាតព្វកិច្ច ក្នុងករណីដូចខាងក្រោម៖

១. អាជ្ញាបណ្ណស្វែងរុករកត្រូវបានបញ្ចប់ ដោយគម្រោងស្វែងរុករករ៉ែបានបញ្ចប់ ហើយសម្បទានិកបានបំពេញកាតព្វកិច្ចនានាបានត្រឹមត្រូវ។

២. អាជ្ញាបណ្ណស្វែងរុករកត្រូវបានបញ្ចប់ ដោយឈានទៅដំណាក់កាលអាជីវកម្មធនធានរ៉ែ ក្រោមអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ហើយសម្បទានិកបានបំពេញកាតព្វកិច្ចនានាបានត្រឹមត្រូវ។

ដើម្បីដកប្រាក់តម្កល់ធានាកាតព្វកិច្ច សម្បទានិកត្រូវស្នើសុំជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែនិងថាមពល ដើម្បីពិនិត្យនិងសម្រេច។ ក្រោយពីពិនិត្យនិងសម្រេចអនុញ្ញាតឱ្យសម្បទានិកដកប្រាក់តម្កល់ធានាកាតព្វកិច្ច ក្រសួងរ៉ែនិងថាមពលនឹងស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានរតនាគារជាតិ) ដើម្បីផ្តល់ការអនុញ្ញាតឱ្យសម្បទានិកដកប្រាក់តម្កល់ធានាកាតព្វកិច្ចវិញ។

អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ និងអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ៦កើត ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែមេសា ឆ្នាំ២០២៥

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**កែវ_រតនៈ**

<u>ចម្លងជូន៖</u>

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានរតនាគារជាតិ
- មន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ



លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤

#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០០០១ រ៉ែ.ឧ.អ.ស.លណន

# សេចក្តីណែនាំ
# ស្តីពី
# ការដាក់ប្រាក់តម្កល់ធានាកាតព្វកិច្ច
# សម្រាប់អាជ្ញាបណ្ណស្វែងរុករក

អនុលោមតាមអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណស្វែងរុករកនិងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ និងក្នុងគោលបំណងឱ្យការដាក់ប្រាក់តម្កល់ធានាកាតព្វកិច្ចនេះប្រកបដោយសមធម៌និងតម្លាភាពចំពោះគ្រប់សម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកទាំងអស់ ក្រសួងរ៉ែនិងថាមពល សូមកំណត់នូវគោលការណ៍ នីតិវិធី និងលក្ខខណ្ឌ អនុវត្តសម្រាប់ការដាក់ ការរឹបអូស និងការដក ប្រាក់តម្កល់ធានាកាតព្វកិច្ចដូចខាងក្រោម៖

## ក. គោលការណ៍នៃការដាក់ប្រាក់តម្កល់ធានាកាតព្វកិច្ច

ប្រាក់តម្កល់ធានាកាតព្វកិច្ចសម្រាប់អាជ្ញាបណ្ណស្វែងរុករក ធ្វើឡើងក្នុងគោលបំណងឱ្យសម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករក (ហៅកាត់ថាសម្បទានិក) អនុវត្តកាតព្វកិច្ច ដោយអនុលោមតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងលក្ខខណ្ឌអាជ្ញាបណ្ណ ដែលមានជាធរមាន។ ការដាក់ប្រាក់តម្កល់ធានាកាតព្វកិច្ច នឹងជំរុញឱ្យសម្បទានិកលើកកម្ពស់ការទទួលខុសត្រូវ ក្នុងការធ្វើប្រតិបត្តិការស្វែងរុករករ៉ែ ស្របតាមកម្មវិធីការងារ និងផែនការចំណាយថវិកា ដែលទទួលបានការយល់ព្រមពីក្រសួងរ៉ែនិងថាមពល ក្នុងសុពលភាពអាជ្ញាបណ្ណរបស់ខ្លួន ចាប់ពីដំណាក់កាលដំបូង រហូតដល់ដំណាក់កាលបញ្ចប់នៃការស្វែងរុករក។

## ខ. ការកំណត់ទំហំប្រាក់តម្កល់ធានាកាតព្វកិច្ច

សម្បទានិកត្រូវដាក់ប្រាក់តម្កល់ធានាកាតព្វកិច្ច សម្រាប់រយៈពេលសុពលភាពនៃអាជ្ញាបណ្ណស្វែងរុករកនីមួយៗ។ ទំហំប្រាក់តម្កល់ធានាកាតព្វកិច្ច ត្រូវបានកំណត់ដូចខាងក្រោម៖

- ស្មើនឹង១០%(ដប់ភាគរយ) នៃទំហំកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាសម្រាប់អាជ្ញាបណ្ណលើកទី១
- ស្មើនឹង៧%(ប្រាំពីរភាគរយ) នៃទំហំកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាសម្រាប់អាជ្ញាបណ្ណលើកទី២
- ស្មើនឹង៦%(ប្រាំមួយភាគរយ) នៃទំហំកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាសម្រាប់អាជ្ញាបណ្ណលើកទី៣ និង



លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh

- ស្មើនឹង៥%(ប្រាំភាគរយ) នៃទំហំកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាសម្រាប់អាជ្ញាបណ្ណលើកទី៤ឡើងទៅ។

ស្របតាមមាត្រា៣៥ នៃអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ ទំហំកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាក្នុងប្រតិបត្តិការស្វែងរុករករ៉ែ បានកំណត់ដូចខាងក្រោម៖

- ចាប់ពីឆ្នាំទី១ ដល់ឆ្នាំទី៣ យ៉ាងតិច ១ ០០០ ០០០(មួយលាន)រៀល ក្នុងផ្ទៃដីមួយគីឡូម៉ែត្រការ៉េ នៃដែនអាជ្ញាបណ្ណក្នុងមួយឆ្នាំ ហើយក្នុងករណីដែនអាជ្ញាបណ្ណតូចជាង ១០០(មួយរយ) គីឡូម៉ែត្រការ៉េ នោះកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាមិនត្រូវតិចជាង ១០០ ០០០ ០០០ (មួយរយលាន)រៀលក្នុងមួយឆ្នាំសម្រាប់ដែនអាជ្ញាបណ្ណទាំងមូល
- ចាប់ពីឆ្នាំទី៤ ដល់ឆ្នាំទី៥ យ៉ាងតិច ៤ ០០០ ០០០ (បួនលាន)រៀល ក្នុងផ្ទៃដីមួយគីឡូម៉ែត្រការ៉េ នៃដែនអាជ្ញាបណ្ណក្នុងមួយឆ្នាំ ហើយក្នុងករណីដែនអាជ្ញាបណ្ណតូចជាង ១០០(មួយរយ) គីឡូម៉ែត្រការ៉េ នោះកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាមិនត្រូវតិចជាង ៤០០ ០០០ ០០០(បួនរយលាន)រៀលក្នុងមួយឆ្នាំសម្រាប់ដែនអាជ្ញាបណ្ណទាំងមូល
- ចាប់ពីឆ្នាំទី៦ ដល់ឆ្នាំទី៧ យ៉ាងតិច ៦ ០០០ ០០០ (ប្រាំមួយលាន)រៀល ក្នុងផ្ទៃដីមួយគីឡូម៉ែត្រការ៉េ នៃដែនអាជ្ញាបណ្ណក្នុងមួយឆ្នាំ ហើយក្នុងករណីដែនអាជ្ញាបណ្ណតូចជាង ១០០(មួយរយ) គីឡូម៉ែត្រការ៉េ នោះកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាមិនត្រូវតិចជាង ៦០០ ០០០ ០០០(ប្រាំមួយរយលាន)រៀលក្នុងមួយឆ្នាំសម្រាប់ដែនអាជ្ញាបណ្ណទាំងមូល
- ចាប់ពីឆ្នាំទី៨តទៅ យ៉ាងតិច ១០ ០០០ ០០០(ដប់លាន)រៀល ក្នុងផ្ទៃដីមួយគីឡូម៉ែត្រការ៉េ នៃដែនអាជ្ញាបណ្ណក្នុងមួយឆ្នាំ ហើយក្នុងករណីដែនអាជ្ញាបណ្ណតូចជាង ១០០(មួយរយ) គីឡូម៉ែត្រការ៉េ នោះកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាមិនត្រូវតិចជាង ១ ០០០ ០០០ ០០០ (មួយពាន់លាន)រៀលក្នុងមួយឆ្នាំសម្រាប់ដែនអាជ្ញាបណ្ណទាំងមូល។

សម្រាប់សុពលភាពនៃអាជ្ញាបណ្ណដែលបានពន្យារបន្ត សម្បទានិកត្រូវដាក់ប្រាក់តម្កល់ធានាកាតព្វកិច្ចបង្គ្រប់ស្របតាមទំហំប្រាក់តម្កល់ធានាកាតព្វកិច្ចដែលបានកំណត់សម្រាប់សុពលភាពអាជ្ញាបណ្ណបន្ទាប់។ ក្នុងករណីទំហំប្រាក់តម្កល់ធានាកាតព្វកិច្ចសម្រាប់សុពលភាពអាជ្ញាបណ្ណបន្ទាប់ តិចជាងទំហំប្រាក់តម្កល់ធានាកាតព្វកិច្ចដែលមានស្រាប់ ត្រូវកំណត់យកប្រាក់តម្កល់ធានាកាតព្វកិច្ចស្មើនឹងប្រាក់តម្កល់ធានាកាតព្វកិច្ចដែលមានស្រាប់នោះ។

ចំពោះប្រភេទចំណាយប្រតិបត្តិការអប្បបរមាក្នុងប្រតិបត្តិការស្វែងរុករករ៉ែ ដែលអនុញ្ញាតឱ្យយកមកគិតបញ្ចូលក្នុងចំណាយប្រតិបត្តិការអប្បបរមា ត្រូវអនុវត្តតាមមាត្រា៩១ នៃអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦។

### គ. នីតិវិធីដាក់ប្រាក់តម្កល់ធានាកាតព្វកិច្ច

មុនពេលទទួលបានអាជ្ញាបណ្ណស្វែងរុករកដំបូងឬអាជ្ញាបណ្ណពន្យារបន្ត សម្បទានិកត្រូវដាក់ប្រាក់តម្កល់ធានាកាតព្វកិច្ច ដោយត្រូវបង់ចូលទៅគណនីទោលនៃរតនាគារជាតិលេខ ០០០០០០០១៣៤៥០ របស់អគ្គនាយកដ្ឋានរតនាគារជាតិ នៅធនាគារជាតិនៃកម្ពុជា បន្ទាប់ពីទទួលបានលិខិតជូនដំណឹងរបស់ក្រសួងរ៉ែនិងថាមពល។



លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh

បន្ទាប់ពីបានតម្កល់ប្រាក់ធានាកាតព្វកិច្ចខាងលើនេះរួច សម្បទានិកត្រូវយកច្បាប់ថតចម្លងនៃ «បណ្ណបញ្ជាក់បានតម្កល់ប្រាក់» មកជូនក្រសួងរ៉ែនិងថាមពល ដើម្បីពិនិត្យនិងទុកជាឯកសារ។

**ឃ. នីតិវិធីនៃការរឹបអូសប្រាក់តម្កល់ធានាកាតព្វកិច្ច**

អនុលោមតាមមាត្រា៣២ នៃអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ ប្រាក់តម្កល់ធានាកាតព្វកិច្ច នឹងត្រូវរឹបអូសជាប្រយោជន៍របស់រដ្ឋ ក្នុងករណីដែលអាជ្ញាបណ្ណស្វែងរុករកត្រូវបានដកហូត។ ក្រសួងរ៉ែនិងថាមពល នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការរឹបអូសប្រាក់តម្កល់ធានាកាតព្វកិច្ច ជូនដល់សម្បទានិក និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានរតនាគារជាតិ) ដើម្បីអនុវត្តនីតិវិធីរឹបអូសទុកជាប្រយោជន៍របស់រដ្ឋ។

**ង. នីតិវិធីនៃការដកប្រាក់តម្កល់ធានាកាតព្វកិច្ច**

សម្បទានិក អាចត្រូវបានអនុញ្ញាតឱ្យដកប្រាក់តម្កល់ធានាកាតព្វកិច្ច ក្នុងករណីដូចខាងក្រោម៖

១. អាជ្ញាបណ្ណស្វែងរុករកត្រូវបានបញ្ចប់ ដោយគម្រោងស្វែងរុករករ៉ែបានបញ្ចប់ ហើយសម្បទានិកបានបំពេញកាតព្វកិច្ចនានាបានត្រឹមត្រូវ។

២. អាជ្ញាបណ្ណស្វែងរុករកត្រូវបានបញ្ចប់ ដោយឈានទៅដំណាក់កាលអាជីវកម្មធនធានរ៉ែ ក្រោមអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ហើយសម្បទានិកបានបំពេញកាតព្វកិច្ចនានាបានត្រឹមត្រូវ។

ដើម្បីដកប្រាក់តម្កល់ធានាកាតព្វកិច្ច សម្បទានិកត្រូវស្នើសុំជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែនិងថាមពល ដើម្បីពិនិត្យនិងសម្រេច។ ក្រោយពីពិនិត្យនិងសម្រេចអនុញ្ញាតឱ្យសម្បទានិកដកប្រាក់តម្កល់ធានាកាតព្វកិច្ច ក្រសួងរ៉ែនិងថាមពលនឹងស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានរតនាគារជាតិ) ដើម្បីផ្តល់ការអនុញ្ញាតឱ្យសម្បទានិកដកប្រាក់តម្កល់ធានាកាតព្វកិច្ចវិញ។

អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ និងអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែមេសា ឆ្នាំ២០២៥

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**កែវ រតនៈ**

<u>ចម្លងជូន៖</u>

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានរតនាគារជាតិ
- មន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ



លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh